ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
សន្និបាត (២០២៥)

# ទស្សនាទាន
# ស្តីពី
# អភិបាលកិច្ចក្រសួងអប់រំ យុវជន និងកីឡា
# តាមរយៈការអនុវត្តថវិកាផ្តោតលើសមិទ្ធកម្ម

រៀបចំដោយ៖ អគ្គលេខាធិការដ្ឋាន
រាជធានីភ្នំពេញ ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៥

# មាតិកា


**មាតិកា** ........ 1

**១. សេចក្តីផ្តើម** ........ 3

**២. ចក្ខុវិស័យ** ........ 3

**៣. បេសកកម្ម** ........ 3

**៤. មូលដ្ឋានគ្រឹះនៃអភិបាលកិច្ចល្អផ្អែកលើការអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម** ........ 4

៤.១. ប្រយោជន៍សាធារណៈ ........ 4

៤.២. តម្លាភាព ........ 5

៤.៣. គណនេយ្យភាព ........ 6

៤.៣. និរន្តរភាព ........ 7

៤.៤. ប្រសិទ្ធភាព ........ 8

**៥. លទ្ធផលសម្រេចបាន** ........ 8

៥ក ធៀបនឹងចំណាយចរន្តជាតិ.យ.ចំណាយចរន្តក្រសួង អ .១. ........ **Error! Bookmark not defined.**

៥.២ .ឥណទានថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា ........ 9

៥.៣ .ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ ........ 10

៥.៤ .ការផ្តល់ថវិកាមត្តេយ្យសិក្សាសហគមន៍ ........ 10

៥.៥ .ការផ្តល់ថវិកាអាហារូបករណ៍សិស្សក្រីក្រជួបការលំបាក ........ 11

៥.៦. ការផ្តល់ថវិកាអាហារូបត្ថម្ភ ........ 11

៥.៧. អង្គភាពថវិកា ........ 12

៥.៨. ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ........ 12

**៦. ទិសដៅអនុវត្តបន្ត** ........ 13

**៧. សេចក្តីសន្និដ្ឋាន** ........ 13


# បញ្ជីរូបភាព


**រូបភាពទី១៖** គោលការណ៍អភិបាលកិច្ចស្របបរិបទអនុវត្តថវិកាផ្តោតលើសមិទ្ធកម្ម ........ 4

**រូបភាពទី២៖** សៀវភៅថវិកាពលរដ្ឋ រៀបចំ និងបោះពុម្ពដោយនាយកដ្ឋានហិរញ្ញវត្ថុ ឆ្នាំ២០២៤៖ ........ 6

**រូបភាពទី៣៖** រចនាសម្ព័ន្ធវាយតម្លៃអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖ ........................... 6
**រូបភាពទី៤៖** តារាងលទ្ធផលសរុបរចនាសម្ព័ន្ធវាយតម្លៃអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ .. 7
**រូបភាពទី៥៖** ចំណាយចរន្តក្រសួង អ.យ.ក ធៀបនឹងចំណាយចរន្តជាតិ ..................................................... 9
**រូបភាពទី៦៖** ឥណទានថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា ១០ឆ្នាំចុងក្រោយ .................................... 9
**រូបភាពទី៧៖** ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ១០ឆ្នាំចុងក្រោយ ........................................ 10
**រូបភាពទី៨៖** ការផ្តល់ថវិកាមត្តេយ្យសិក្សាសហគមន៍០៨ឆ្នាំចុងក្រោយ ................................................... 10
**រូបភាពទី៩៖** ការផ្តល់ថវិកាអាហារូបករណ៍សិស្សក្រីក្រជួបការលំបាក ០៩ឆ្នាំចុងក្រោយ ................................ 11
**រូបភាពទី១០៖** ការផ្តល់ថវិកាអាហារូបត្ថម្ភ ........................................................................................ 12
**រូបភាពទី១១៖** ស្ថានភាពអង្គភាពថវិកា ............................................................................................. 12

## ១. សេចក្តីផ្តើម

ឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលថ្មីនីតិកាលទី៧ ជាពិសេស បញ្ចកោណទី១៖ ការអភិវឌ្ឍមូលធនមនុស្ស ក្នុងនោះការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ការលើកកម្ពស់សុខភាពនិងសុខុមាលភាពប្រជាជន ការពង្រឹងប្រព័ន្ធគាំពារសង្គមនិងប្រព័ន្ធស្បៀង ព្រមទាំងការពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន ក្រសួងអប់រំ យុវជន និងកីឡានៅតែបន្តធ្វើការងារយ៉ាងសកម្ម ដោយបានក្លាយទៅជាទម្លាប់នៃការអនុវត្តការដ្ឋានកំណែទម្រង់យុទ្ធសាស្ត្រវិស័យអប់រំដែតឈប់ឈរ ឆ្ពោះទៅមុខជានិច្ចប្រកបដោយភាពបុរេសកម្ម និងការទទួលខុសត្រូវខ្ពស់ នៃវិជ្ជាជីវៈក្នុងនាមជាស្ថាប័នអប់រំ។

ទស្សនាទាននេះ បានបង្កើតឡើងសម្រាប់លើកកម្ពស់ចំណេះដឹងលើការផ្សារភ្ជាប់គោលការណ៍អភិបាលកិច្ចទៅនឹងការអនុវត្តថវិកាផ្តោតលើសមិទ្ធកម្ម ដើម្បីឱ្យគ្រប់ស្ថានប័នសាធារណៈ ស្ថាប័នឯកជន ពិសេសសាធារណៈជនអាចមានលទ្ធភាពយល់ដឹងអំពីព័ត៌មានថវិកាជាតិដែលក្រសួងអប់រំ យុវជន និងកីឡា បានប្រើប្រាស់ដោយផ្អែកលើគោលការណ៍សំខាន់ៗជាមូលដ្ឋាននៃទស្សនាទានអភិបាលកិច្ច ព្រមទាំងជាផ្នែកមួយនៃយន្តការផ្តល់នូវព័ត៌មានសង្ខេប ងាយយល់ សមស្របទៅតាមបរិបទ និងប្រើប្រាស់វិធីសាស្ត្រសាមញ្ញៗ។

## ២. ចក្ខុវិស័យ

ចក្ខុវិស័យនៃអភិបាលកិច្ចល្អតាមរយៈការអនុវត្តថវិកាសមិទ្ធកម្ម ក្នុងបរិបទក្រសួងអប់រំ យុវជន និងកីឡាទទួលរងឥទ្ធិពលពីចក្ខុវិស័យនៃគោលនយោបាយអប់រំ ដែលកំណត់ថា ប្រជាជនកម្ពុជា "**មានចំណេះដឹងខ្ពស់ និងជំនាញមួយយ៉ាងតិចប្រចាំជីវិត**» តាមរយៈការបង្កើតប្រព័ន្ធថវិកាផ្សារភ្ជាប់ទៅនឹងលក្ខខណ្ឌតម្លាភាព គណនេយ្យភាព និងលទ្ធផលដែលបង្កើនប្រសិទ្ធភាពនៃការបែងចែកធនធាន បង្កើនប្រសិទ្ធភាពហិរញ្ញវត្ថុ និងកែលម្អលទ្ធផលអប់រំ។ ទស្សនៈក៏ជាផ្នែកមួយក្នុងការសម្រេចគោលបំណងធានាថា ការសម្រេចចិត្តលើថវិកាស្របតាមគោលដៅអភិវឌ្ឍន៍ជាតិ លើកកម្ពស់សមធម៌ក្នុងវិស័យអប់រំ គាំទ្រ និងឆ្លើយតបជាវិជ្ជមានលើកំណើននៃតម្រូវការគ្រប់ទិដ្ឋភាព ប្រកបដោយចីរភាពក្នុងវិស័យ។

## ៣. បេសកកម្ម

បេសកកម្ម ដើម្បីពង្រឹងយន្តការអភិបាលកិច្ចដោយបង្កើនតម្លាភាព គណនេយ្យភាព និងការចូលរួមពីភាគីពាក់ព័ន្ធក្នុងដំណើរការរៀបចំថវិកា។ វាស្វែងរកការអនុវត្តថវិកាផ្អែកលើការអនុវត្ត ដែលផ្តល់អាទិភាពដល់ការសម្រេចចិត្តផ្អែកលើភស្តុតាង ធានាថាថវិកាត្រូវបានបែងចែកប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវការកែលម្អការអប់រំដែលអាចវាស់វែងបាន និងផ្តោតលើកត្តាចាំបាច់ដូចខាងក្រោម៖

- ការកសាងសមត្ថភាពនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុ
- ពង្រឹងបាននូវយន្តការត្រួតពិនិត្យ និងដំណើរការវាយតម្លៃ
- លើកកម្ពស់ការទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ ជាពិសេសសម្រាប់សហគមន៍ដែលខ្វះខាត និងជួបការលំបាក
- កំណត់ចេញជាទិសដៅក្នុងការបង្កើតក្របខណ្ឌអភិបាលកិច្ច រួមបញ្ចូលជាមួយបច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិមិត្ត (AI) ជាជំនួយ និងជាយន្តការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព ការប្រឡងប្រណាំង ស្របតាម

ទិសដៅរួមដើម្បីការអភិវឌ្ឍវិស័យអប់រំសម្រាប់រយៈពេលមធ្យម និងរយៈពេលវែង ស្របតាមបរិបទការវិវត្តរបស់សកលលោក ។

## ៤. មូលដ្ឋានគ្រឹះនៃអភិបាលកិច្ចល្អផ្អែកលើការអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម

អភិបាលកិច្ចល្អតាមរយៈការអនុវត្តថវិកាផ្តោតលើសមិទ្ធកម្ម បានវិវត្តឱ្យមានការធ្វើសមាហរណកម្មនៃគោលការណ៍អភិបាលកិច្ចល្អ ជាមួយនឹងការអនុវត្តថវិកា និងការកែប្រែពីបញ្ហាប្រឈមទៅជាកាលានុវត្តភាព ដើម្បីឈានដល់ការសម្រេចបានជាបន្តបន្ទាប់ នៃគោលបំណងជានយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយផ្សារភ្ជាប់ជាមូលដ្ឋានក្នុងការដោះស្រាយបញ្ហា ស្របតាមបរិបទបំរែបំរួលឥតឈប់ឈរនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ទិដ្ឋភាពគោលនយោបាយ និងសមត្ថភាពអង្គភាពអនុវត្តថវិកា ដើម្បីសម្រេចបាននូវ **"ការធានាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អកាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត"**។

គោលការណ៍អភិបាលកិច្ចល្អ ត្រូវបានកំណត់ជាអាទិភាពក្នុងការអនុវត្តមានភាពដូចគ្នា ឬខុសគ្នា មានតិច ឬច្រើន អាស្រ័យលើបរិបទនៃទិដ្ឋភាពបេសកកម្មផ្សេងៗគ្នានៃវិស័យ ឬអនុវិស័យនីមួយៗ។ ជាយន្តការអនុវត្តកន្លងមក ស្របតាមបរិបទការអនុវត្តថវិកាផ្តោតលើសមិទ្ធកម្ម ក្រសួងអប់រំ យុវជន និងកីឡាបានដាក់អាទិភាពលើគោលការណ៍ដូចខាងក្រោម៖




**រូបភាពទី១៖** គោលការណ៍អភិបាលកិច្ចស្របបរិបទអនុវត្តថវិកាផ្តោតលើសមិទ្ធកម្ម

### ៤.១. ប្រយោជន៍សាធារណៈ

ស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤-២០២៨ ក្រសួងអប់រំ យុវជន និងកីឡា (ក្រសួង អយក)មានចក្ខុវិស័យ ជំរុញឱ្យប្រជាជនកម្ពុជា **"មានចំណេះដឹងខ្ពស់ និងជំនាញមួយយ៉ាងតិចប្រចាំជីវិត"** ប្រកបដោយអំណត់ធន់ សហគ្រិនភាព នវានុវត្តន៍ និងសីលធម៌ប្រពៃ ដោយរដ្ឋធានាផ្តល់សេវាអប់រំជាមូលដ្ឋានសម្រាប់ទាំងអស់គ្នាយ៉ាងតិចត្រឹមថ្នាក់ទី៩ បំពាក់ជំនាញ និងបច្ចេកវិទ្យាដែលជាតម្រូវការ ទីផ្សារការងារ និងធុរកិច្ច ពង្រឹងការបណ្តុះបណ្តាល និងផ្លាស់ប្តូរជំនាញ ស្របនឹងតម្រូវការទីផ្សារការងារ ពង្រឹងគុណភាពវិស័យឧត្តមសិក្សាឱ្យក្លាយជាមណ្ឌលមូល ធនបញ្ញាជាតិ និងឃ្លាំងពុទ្ធិសកល និង

យកចិត្តទុកដាក់ លើជីវភាពគ្រូបង្រៀន បុគ្គលិកសិក្សា និងសាស្ត្រាចារ្យ។ ស្របតាមបេសកកម្ម ការធ្វើបរិវត្តកម្មប្រព័ន្ធអប់រំឆ្ពោះទៅរកការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន ភាពពាក់ព័ន្ធ និងភាពធន់ ដើម្បីដោះស្រាយបញ្ហាការសិក្សា និងកសាងសង្គមប្រកបដោយសមធម៌ បរិយាបន្ន ចីរភាព និងសង្គមផ្អែកលើពុទ្ធិ ស្របតាមបំណងប្រាថ្នាប្រទេសកម្ពុជា។ ក្នុងន័យនេះ ជាការឆ្លុះបញ្ចាំងដល់ការគិតគូរលើអនាគតកម្ពុជា និងស្របតាមអាទិភាពឆ្លើយតបនឹងយុទ្ធសាស្ត្រ បញ្ចកោណ ដំណាក់កាលទី១ ក្រសួង អយក បានកំណត់អាទិភាពចំនួន៨ ក្នុងទិសដៅក្នុងការសម្រេចឱ្យបានកាន់ល្អប្រសើរជាបន្តបន្ទាប់ តាមរយៈផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤-២០២៨ ៖

- **អាទិភាពទី១៖** ការពង្រឹងអភិបាលកិច្ចសាលារៀន
- **អាទិភាពទី២៖** ពិនិត្យ និងកែសម្រួលកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សា
- **អាទិភាពទី៣៖** ការលើកកម្ពស់សុខភាពសិក្សា
- **អាទិភាពទី៤៖** ការលើកទឹកចិត្តលើការចូលរួមពីមាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍
- **អាទិភាពទី៥៖** ការជំរុញការអប់រំឌីជីថល
- **អាទិភាពទី៦៖** ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពក្នុងគ្រឹះស្ថានឧត្តមសិក្សា
- **អាទិភាពទី៧៖** ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព
- **អាទិភាពទី៨៖** អភិវឌ្ឍការអប់រំកាយ និងកីឡា

## ៤.២. តម្លាភាព

តម្លាភាពក្នុងបរិបទនៃអភិបាលកិច្ចល្អតាមរយៈការអនុវត្តថវិកាផ្តោតលើសមិទ្ធកម្ម ឈរលើមូលដ្ឋានលើការផ្តល់បរិយាកាសសមប្រកបមួយលើការផ្សព្វផ្សាយ ឬផ្តល់នូវព័ត៌មានច្បាស់លាស់ ដែលអាចអោយសាធារណៈជនស្វែងយល់ និងដឹងពីគ្រប់ដំណើរការទាក់ទងនឹងការគ្រប់គ្រង និងវដ្តថវិក។




ក្រសួងអប់រំ យុវជន និងកីឡាជារៀងរាល់ឆ្នាំតែងរៀបចំអង្គសន្និបាត ដើម្បីបូកសរុបលទ្ធផលការងារ និងផ្សព្វផ្សាយដើម្បីឱ្យសាធារណៈជនស្វែងយល់ពីស្ថានភាពរួមមាៈ ១). វឌ្ឍនភាព ២). លទ្ធផលរួមរបស់ក្រសួង ៣). លទ្ធផលតាមអនុវិស័យ ៤). ទិសដៅអនុវត្តបន្ត ជាពិសេសការគ្រប់គ្រងស្ថានភាពហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង។

លើសពីនេះ នៅខែមីនា ឆ្នាំ២០២៤ នាយកដ្ឋានហិរញ្ញវត្ថុ បោះពុម្ពផ្សាយនូវ "**សៀវភៅថវិកាពលរដ្ឋ**" សម្រាប់លើកកម្ពស់ចំណេះដឹងផ្នែកថវិកាដែលត្រូវបានរៀបចំឡើង ដើម្បីឱ្យពលរដ្ឋភាគច្រើន មានលទ្ធភាពយល់ដឹងអំពីព័ត៌មានថវិកាជាតិដែលក្រសួងអប់រំ យុវជន និងកីឡាបានប្រើប្រាស់ ព្រមទាំងផ្តល់នូវព័ត៌មានសង្ខេប ងាយយល់ ដោយរៀបចំទិន្នន័យថវិការដ្ឋឱ្យសមស្របទៅតាមបរិបទ និងប្រើប្រាស់វិធីសាស្ត្រសាមញ្ញៗ។






មាតិកា

១. សេចក្តីផ្តើម ........ 1
២. ពាក្យគន្លឹះ ........ 2
៣. ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា ........ 5
៤. រចនាសម្ព័ន្ធថវិកាកម្មវិធី ........ 6
៤.១. គោលបំណងគោលនយោបាយ ........ 6
៤.២. ការរៀបចំកម្មវិធី ........ 6
៤.៣. ការរៀបចំអង្គភាពថវិកា ........ 8
៥. ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ ២០២៤ ........ 9
៥.១. ស្ថានភាពចំណូល ........ 9
៥.២. ស្ថានភាពចំណាយរបស់ក្រសួងក្នុងឆ្នាំ២០២៤ ........ 10
៥.២.១. ស្ថានភាពចំណាយរបស់ក្រសួង ........ 11
៥.២.២. ថវិការបស់អង្គភាពរដ្ឋបាលកណ្តាល ........ 19
៥.២.៣. ថវិការបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ........ 21
៥.២.៤. ការផ្ទេរថវិកា ៣មុខងារឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ........ 22
៥.៣. មុខសញ្ញាចំណាយសំខាន់ៗរបស់ក្រសួង ........ 24
៥.៣.១. ថវិកាបន្ទុកបុគ្គលិក ........ 26
៥.៣.២. ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ ........ 27
៥.៣.៣. ថវិកាអាហារូបករណ៍សិស្សក្រីក្រ ........ 28
៥.៣.៤. កម្មវិធីផ្តល់អាហារតាមសាលារៀន ........ 29
៥.៣.៥. ថវិកាមត្តេយ្យសិក្សាសហគមន៍ ........ 30
៥.៣.៦. ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ........ 32
៥.៣.៧. ការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ ........ 33
៥.៣.៨. ការប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ........ 34
៥.៣.៩. ការអភិវឌ្ឍយុវជន ........ 35
៦. សូចនាករសមិទ្ធកម្ម និងគោលដៅ ........ 36
៧. ឯកសារយោង ........ 39

i

រូបភាពទី២៖ សៀវភៅថវិកាពលរដ្ឋ រៀបចំ និងបោះពុម្ពដោយនាយកដ្ឋានហិរញ្ញវត្ថុ ឆ្នាំ២០២៤៖

## ៤.៣. គណនេយ្យភាព

យន្តការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ បានរៀបចំឡើងដោយមានកិច្ចសហការជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីត្រីមាសទី១ ឆ្នាំ២០២៤។ ការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងអប់រំ យុវជន និងកីឡារៀបចំក្នុងគោលបំណង ដើម្បី **កំណត់ភាពខ្លាំង និងភាពខ្សោយ** នៃស្ថានភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងផ្តល់លទ្ធភាពកំណត់លំដាប់អាទិភាព និងភាពប្រទាក់ក្រឡាគ្នា នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងក្របខណ្ឌនៃផែនការសកម្មភាពរួម នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទិសដៅនៃការកសាងថវិកាសមិទ្ធកម្ម។




រូបភាពទី៣៖ រចនាសម្ព័ន្ធវាយតម្លៃអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖

ក្រសួងអប់រំ យុវជន និងកីឡាបានចូលរួមការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីអនុវត្តក្របខណ្ឌវាយតម្លៃ សសរស្តម្ភចំនួន៧ រួមមាន៖

- ភាពជឿទុកចិត្តនៃថវិកា

- តម្លាភាពហិរញ្ញវត្ថុសាធារណៈ
- ការគ្រប់គ្រងទ្រព្យសកម្ម
- ការរៀបចំថវិកាផ្សារភ្ជាប់គោលនយោបាយ
- ការប៉ាន់ប្រមាណ និងការត្រួតពិនិត្យការអនុវត្តថវិកា
- កិច្ចបញ្ជិកាគណនេយ្យ និងការរៀបចំរបាយការណ៍
- ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់

ជាលទ្ធផលក្នុងការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់ឆ្នាំ២០២១-២០២៣ ដែលរៀបចំឡើងដោយមានកិច្ចសហការ ជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

| ពិន្ទុ | A | B+ | B | C+ | C | D+ | D | សរុប |
|---|---|---|---|---|---|---|---|---|
| ចំនួន | ៥ | ៤ | ១ | ៣ | ៥ | ១ | ៥ | ២៥នាក់ |

រូបភាពទី៤៖ តារាងលទ្ធផលសរុបរចនាសម្ព័ន្ធវាយតម្លៃអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ៤.៤. និរន្តរភាព

គោលនយោបាយអប់រំ បានកំណត់ "**ធានាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត**"។

ក្នុងន័យនេះ ស្របតាមគោលការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីធានានិរន្តរភាពនៃវិស័យអប់រំ ក្រសួង អយក បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ ដែលបានរៀបចំ ៥កម្មវិធីអាទិភាពរួមមាន៖

- **កម្មវិធីអាទិភាពទី១៖** កំណែទម្រង់សាលារៀន ដើម្បីឱ្យការចូលរៀនប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន
- **កម្មវិធីអាទិភាពទី២៖** កែលម្អការចូលរៀន គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា និងការស្រាវជ្រាវ និងនវានុវត្តន៍
- **កម្មវិធីអាទិភាពទី៣៖** លើកកម្ពស់ជំនាញសតវត្សរ៍ទី២១ សម្រាប់យុវជន
- **កម្មវិធីអាទិភាពទី៤៖** ការអភិវឌ្ឍសកម្មភាពហាត់ប្រាណ ការអប់រំកាយ និងកីឡា
- **កម្មវិធីអាទិភាពទី៥៖** លើកកម្ពស់ការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម។

ឆ្លើយតបតាមគោលនយោបាយអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បាន នឹងកំពុងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាផ្នែកមួយដ៏សំខាន់ នៃការកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងន័យនេះ ក្រសួងបានរៀបចំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានានិរន្តរភាពដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងកែលម្អការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើង ដើម្បីធានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពដែលជាធាតុមួយដ៏សំខាន់សម្រាប់អភិវឌ្ឍប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្រ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយរយៈពេលវែង និងមានចក្ខុវិស័យប្រកបដោយមហិច្ឆតា ដើម្បីកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាឱ្យស្របទៅនឹងកម្រិតស្តង់ដាអន្តរជាតិតាមរយៈ៤ដំណាក់កាល៖

១. ភាពជឿទុកចិត្តបាននៃថវិកា ដែលបានអនុវត្តពីឆ្នាំ២០០៥ ដល់២០០៨

២. គណនេយ្យភាពហិរញ្ញវត្ថុ ដែលបានអនុវត្តពីឆ្នាំ២០០៩ ដល់២០១៥
៣. ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដែលបានអនុវត្តពីឆ្នាំ២០១៦ ដល់២០២០
៤. គណនេយ្យភាពសមិទ្ធកម្ម ដែលបានអនុវត្តពីឆ្នាំ២០២១ ដល់២០២៥ ។

ស្របតាមទិសដៅលើកកម្ពស់អភិបាលកិច្ចល្អតាមរយៈការអនុវត្តថវិកាផ្តោតលើសមិទ្ធកម្ម ក្រសួង អយក បាន និង កំពុងបន្តការអភិវឌ្ឍយន្តការ និងប្រព័ន្ធព័ត៌មានវិទ្យាចាំបាច់ជាបន្តបន្ទាប់ ក្នុងការធានាបាននូវប្រសិទ្ធភាព គណនេយ្យភាព ពិសេសធានាបាននូវនិរន្តរភាពការបំពេញបេសកកម្មរបស់ក្រសួង អយក មានជាអាទិ៍៖

- ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS)
- ប្រព័ន្ធកត់ត្រាទិន្នន័យសិស្ស (STS)
- ការអនុវត្តប្រព័ន្ធ HRMIS
- ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (EMIS)
- ប្រព័ន្ធគ្រប់គ្រងព័ត៌មានសាលារៀន (SIS)
- ប្រព័ន្ធឌីជីថលសម្រាប់ការសិក្សាពីចម្ងាយ (Duraseksa)
- ប្រព័ន្ធគ្រប់គ្រងគ្រឹះស្ថានសិក្សា (SMIS)។

### ៤.៥. ប្រសិទ្ធភាព

ក្នុងអភិបាលកិច្ច ការចាត់ចែងល្អ ត្រូវផ្សារភ្ជាប់ជាមួយប្រសិទ្ធភាព តាមរយៈរចនាសម្ព័ន្ធគ្រប់គ្រងក្នុងការប្រើប្រាស់ធនធានឱ្យអស់ពីលទ្ធភាព។ ដើម្បីឱ្យមានប្រសិទ្ធភាពក្នុងការអនុវត្ត ត្រូវពិចារណាលើចំណុចចំនួន០៦ ដូចខាងក្រោម៖

- ការប្រើប្រាស់ធនធាន (ធនធានមនុស្ស ហិរញ្ញវត្ថុ សម្ភារៈ ពេលវេលា) ឱ្យបានត្រឹមត្រូវ
- ការអនុវត្តសកម្មភាពដែលជាអាទិភាពខ្ពស់
- ជៀសវាងការអនុវត្តនូវការិយាធិបតេយ្យ
- ការគិតគូរយៈពេលវែងលើការប្រើប្រាស់ធនធានគ្រប់រូបភាព
- ភាពស្មោះត្រង់ និងសុចរិតភាព
- ការសម្រេចចិត្តតាមបែបរិមជ្ឈការ។

## ៥. លទ្ធផលសម្រេចបាន

ស្របតាមការអនុវត្តឈរលើមូលដ្ឋានអភិបាលកិច្ចល្អ ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចបាននូវសមិទ្ធផលសំខាន់ជាបន្តបន្ទាប់គួរឱ្យកត់សម្គាល់ដូចខាងក្រោម៖

### ៥.១. ចំណាយចរន្តក្រសួង អ.យ.ក ធៀបនឹងចំណាយចរន្តជាតិ



- ឆ្នាំ២០២៣ គិតបញ្ចូលថវិកាផ្ទេរពាមុខងារនៅខេត្តបាត់ដំបង
- ឆ្នាំ២០២៤ គិតបញ្ចូលថវិកាផ្ទេរពាមុខងារទូទាំងប្រទេស
- ឆ្នាំ២០២៥ គិតបញ្ចូលថវិកាផ្ទេរពាមុខងារទូទាំងប្រទេស និងថវិកាដំណើរការការិយាល័យ អយក នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

**រូបភាពទី៥៖ ចំណាយចរន្តក្រសួង អ.យ.ក ធៀបនឹងចំណាយចរន្តជាតិ**

- **ការកើនឡើងនៃថវិកាចរន្តរបស់ក្រសួងអប់រំ៖** ថវិកាចរន្តរបស់ក្រសួងអប់រំ យុវជន និងកីឡាបានកើនឡើងចាប់ពី ៤៩៥,១ លានដុល្លារ (២០១៦) ទៅ ៩៧៧,៨លានដុល្លារ (២០២៥)។ ការកើនឡើងនេះបង្ហាញពីការយកចិត្តទុកដាក់ និងវិនិយោគទៅលើវិស័យអប់រំ យុវជន និងកីឡា ដែលជាគន្លឹះដ៏សំខាន់សម្រាប់អភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាល។
- **ភាគរយនៃចំណាយចរន្តជាតិ៖** បើប្រៀបធៀបទៅនឹងចំណាយចរន្តជាតិ គឺមានភាពប្រែប្រួលចន្លោះ ១៥,៥% ដល់ ១៨,៣% ដែលកំពូលខ្ពស់បំផុត គឺនៅឆ្នាំ២០១៨ (១៨,៣%) និងធ្លាក់ចុះខ្លាំងក្នុងឆ្នាំ២០២៤(១៥,៧%) និងមានកំណើនបន្តិចមកវិញនៅឆ្នាំ២០២៥ (១៦,៨%)។

## ៥.២ .ឥណទានថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា




| | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|---|---|---|---|---|
| ចំណាយចរន្ត | 2,029,896.9 | 2,383,672.6 | 2,705,456.0 | 2,949,604.0 | 3,207,220.0 | 3,024,413.0 | 3,040,826.0 | 3,512,319.0 | 3,736,011.0 | 4,008,930.4 |
| ចំណាយមូលធន (ក្នុងប្រទេស) | 40,000.0 | 90,000.0 | 420,000.0 | 280,000.0 | 185,000.0 | 90,000.0 | 60,000.0 | 60,000.0 | 80,000.0 | 80,000.0 |

ចំណាយចរន្ត    ចំណាយមូលធន (ក្នុងប្រទេស)

**រូបភាពទី៦៖** ឥណទានថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា ១០ឆ្នាំចុងក្រោយ

- **ចំណាយចរន្ត៖** បង្ហាញនូវកំណើនឥណទានថវិកាជាលំដាប់ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ដែលកើនឡើងទ្វេដង ពោលគឺក្នុងរង្វង់ ២ទ្រីលានរៀល នៅឆ្នាំ២០១៦ មក ៤,០៨ ទ្រីលានរៀល នៅឆ្នាំ២០២៥ ទន្ទឹមនឹងនោះ យើងសង្កេតឃើញថា មានការធ្លាក់ចុះនៅឆ្នាំ២០២១ ដែលនៅពេលនោះគឺបណ្តាលមកពីការរីករាលដាលនៃជំងឺ COVID-19។
- **ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេស៖** រក្សានូវចំនួនថេរ គឺ ៨០,០០០លានរៀល នៅរយៈពេល ២ឆ្នាំចុងក្រោយនេះ។
- សម្រាប់ឆ្នាំ២០២៥ ដែលមានឥណទានសរុបចំនួនក្នុងរង្វង់ ៤.០៨ទ្រីលានរៀល គឺ**បានកើនឡើងចំនួន ១០៧,២% ធៀបនឹងឥណទានថវិកាឆ្នាំ២០២៤ និង ១០១,៧% ធៀបនឹងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៥-២០២៧** ដែលនេះបង្ហាញពីចំណុចល្អមួយឆ្លើយតបទៅនឹងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលជាចេតនា គឺកាត់បន្ថយគម្លាតរវាងគម្រោងថវិកាប្រចាំឆ្នាំ និងBSP ដែលតួលេខនេះ គឺគិតបញ្ចូលថវិកាផ្ទេរពាមុខងារទូទាំងប្រទេស និងថវិកាដំណើរការការិយាល័យ អយក នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## ៥.៣ .ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ




| | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|---|---|---|---|---|
| ក្រៅបន្ទុកបុគ្គលិក (ច្បាប់) | 403,058.8 | 447,386.8 | 524,710.0 | 595,250.0 | 636,429.6 | 601,518.5 | 586,820.6 | 629,932.0 | 693,555.3 | 704,601.4 |
| ថវិកា SOF | 50,870.9 | 62,003.6 | 74,812.8 | 130,572.0 | 124,865.4 | 140,158.3 | 141,224.1 | 152,538.4 | 171,887.0 | 176,770.4 |
| %ក្រៅបន្ទុកបុគ្គលិក | 12.6% | 13.9% | 14.3% | 21.9% | 19.6% | 23.3% | 24.1% | 24.2% | 24.8% | 25.1% |
| ធៀប SOF ឆ្នាំចាស់ | 110.1% | 121.9% | 120.7% | 174.5% | 95.6% | 112.2% | 100.8% | 108.0% | 112.7% | 102.8% |

ក្រៅបន្ទុកបុគ្គលិក (ច្បាប់)  ថវិកា SOF  %ក្រៅបន្ទុកបុគ្គលិក  ធៀប SOF ឆ្នាំចាស់

**រូបភាពទី៧៖ ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ១០ឆ្នាំចុងក្រោយ**

**បញ្ជាក់៖**

- ថវិកាក្រៅបន្ទុកបុគ្គលិកឆ្នាំ២០២០ ដល់២០២៥ គិតបញ្ចូលថវិកាផ្ទេរថ្នាក់ក្រោមជាតិ
- ថវិកាSOF ឆ្នាំ២០២៣ គិតបញ្ចូលថវិកាសម្រាប់គាំទ្របន្ថែមជូនសាលារៀនសាធារណៈ១២០សាលា (លិខិត ១១៦៨២ សហវ.ស.ល.អថ) ចំនួន ៤ ២០៦លានរៀល
- ថវិកា SOF ឆ្នាំ២០២៤ គិតបញ្ចូលថវិកាសម្រាប់គាំទ្រស្តង់ដាសាលារៀនគំរូ (លិខិត៧២២៨ សហវ) ចំនួន ១៤ ៧៣២,៤ លានរៀល
- ក្រៅបន្ទុកបុគ្គលិក២០២៥ ដកថវិកាអាហារូបករណ៍ដែលត្រូវផ្ទេរទៅមូលនិធិជាតិជំនួយសង្គមចំនួន ១១៥ ០០០ លានរៀល ថវិកាSOF ២០២៥ ថែម ១៦ ៥០០លានរៀល សម្រាប់គាំទ្រស្តង់ដាសាលាគំរូ។

## ៥.៤ .ការផ្តល់ថវិកាមត្តេយ្យសិក្សាសហគមន៍

មត្តេយ្យសិក្សាសហគមន៍ ជាកន្លែងដែលបង្កើតឡើង និងគាំទ្រដោយក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងមានក្រសួងពាក់ព័ន្ធមួយចំនួនចូលរួម សម្រាប់កុមារអាយុពី ៣ឆ្នាំ ដល់៥ឆ្នាំ អាចរហូតដល់ ៦ឆ្នាំ រួមទាំងជាចំណែកក្នុងការជួយកុមារនៅតំបន់ជនបទដាច់ស្រយាលអាចទទួលបានសេវាថែទាំ និងអប់រំប្រកបដោយនិរន្តរភាព។



| | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|---|---|---|
| ចំនួនថ្នាក់ | 600 | 850 | 1,050 | 1,250 | 1,250 | 1,305 | 1,438 | 1,438 |
| ទឹកប្រាក់ (លានរៀល) | 4,980.0 | 7,259.0 | 8,967.0 | 10,675.0 | 10,675.0 | 11,387.5 | 14,006.1 | 14,402.5 |

ចំនួនថ្នាក់  ទឹកប្រាក់ (លានរៀល)

**រូបភាពទី៨៖** ការផ្តល់ថវិកាមត្តេយ្យសិក្សាសហគមន៍០៨ឆ្នាំចុងក្រោយ

អនុគណនី ៦១០៩៣ (បុគ្គលិកសម្ភពហភាពសាធារណៈផ្សេងៗ) ផ្ដល់ជូនចំនួន ១៣ ៦៣២,២ លានរៀល **កើនចំនួន ៣៤៥,១ លានរៀល ត្រូវជា ២,៦% ធៀបនឹងច្បាប់ឆ្នាំ ២០២៤** សម្រាប់ចំណាយបើកផ្ដល់ប្រាក់ខែជូនគ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ចំនួន ១ ៤៣៨នាក់ (១ ៤៣៨ ថ្នាក់មត្តេយ្យសិក្សាសហគមន៍) ដោយគិតប្រាក់ខែ ៧៩ ម៉ឺនរៀល/១នាក់ សម្រាប់១២ ខែ។

## ៥.៥ .ការផ្ដល់ថវិកាអាហារូបករណ៍សិស្សក្រីក្រជួបការលំបាក




**រូបភាពទី៩៖** ការផ្ដល់ថវិកាអាហារូបករណ៍សិស្សក្រីក្រជួបការលំបាក ០៩ឆ្នាំចុងក្រោយ

ថវិកាអាហារូបករណ៍សិស្សក្រីក្រជួបការលំបាក ក្រោយពីការចាកចេញពីវិបត្តិកូវីត១៩ មានការកើនឡើងជាប្រចាំដោយ ៦៤ ០៩២.៧ លាន (២០២១) ដល់ ១១៥ ០០០ លាន (២០២៥)។

## ៥.៦. ការផ្ដល់ថវិកាអាហារូបត្ថម្ភ

កម្មវិធីផ្ដល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ បានអនុវត្តនៅកម្ពុជាតាំងពីឆ្នាំ១៩៩៩ ដោយចាប់ផ្ដើមពី ៦៤សាលា មានសិស្ស ៣៧ ៥០០នាក់ ដោយប្រើប្រាស់ស្បៀងដែលផ្ដល់ពីកម្មវិធីស្បៀងអាហារពិភពលោក ហើយកម្មវិធីនេះបានពង្រីកវិសាលភាពជាបន្តបន្ទាប់រហូតមកដល់ឆ្នាំ២០១៤។

គោលបំណងនៃកម្មវិធីនេះគឺ ១) បង្កើនអាហារូបត្ថម្ភចម្រុះដល់កុមារ ជួយឱ្យមានសុខភាពល្អ ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ រួមចំណែក លើកស្ទួយផ្នែកសុខភាព សតិបញ្ញា ស្មារតី និងអារម្មណ៍កុមារឱ្យទទួលបានការរៀនសូត្រកាន់តែប្រសើរ។ ២) បង្កើនអត្រាចូលរៀននិងមករៀនបានទៀងទាត់ ទាន់ពេលវេលា បង្កើនអត្រាឡើងថ្នាក់ អត្រាបញ្ចប់ភូមិសិក្សានៅកម្រិតបឋមសិក្សា និងកាត់បន្ថយអត្រាបោះបង់ការសិក្សា និង៣) បង្កើនចំណូលជូនប្រជាពលរដ្ឋក្នុងសហគមន៍គោលដៅតាមរយៈការជំរុញឱ្យមានផលិតកម្មស្បៀងចម្រុះ ដើម្បីផ្គត់ផ្គង់ដល់សាលារៀន និងកាត់បន្ថយបន្ទុកចំណាយរបស់មាតាបិតាសិស្សបានមួយកម្រិត។

ឆ្នាំសិក្សា២០១៩-២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចទទួលការផ្ទេរសាលារៀនគោលដៅពីកម្មវិធីស្បៀងអាហារពិភពលោកជាបណ្ដើរៗ មកអនុវត្តជាកម្មវិធីជាតិ ក្រោមរូបភាពកម្មវិធីអាហារពេលព្រឹក និងអាហារថ្ងៃត្រង់ដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ដែលមានចំនួន៦ ខេត្ត ស្មើនឹង២០៥សាលារៀន និងមានចំនួនសិស្សទទួលទានអាហារចំនួន ៤០ ៩០៥នាក់ ចំណាយថវិកាចំនួន ៧ ០៧២.៤លានរៀល ជាឆ្នាំដំបូង។

នៅឆ្នាំ២០២៤ ក្រសួង អយក ចំណាយលើកម្មវិធីអាហារូបត្ថម្ភតាមសាលារៀន ដោយបានពង្រីកគោលដៅចំនួន ១០ ខេត្ត ស្មើនឹង៥៩៣សាលារៀន ដែលមានចំនួនសិស្សទទួលទានអាហារចំនួន ១៤៨ ៥៦៥នាក់ ចំណាយថវិកាចំនួន ២២ ៧១២.១លានរៀល។




**រូបភាពទី១០៖** ការផ្តល់ថវិកាអាហារូបត្ថម្ភ

## ៥.៧. អង្គភាពថវិកា

ក្រសួងបានប្រែក្លាយអង្គភាពថវិកា ទៅជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញជាបន្តបន្ទាប់ ជាពិសេសអង្គភាពថវិកានៅតាមមន្ទីរអយក រាជធានីខេត្ត។ អង្គភាពថវិការបស់ក្រសួង អយក សម្រាប់ឆ្នាំ២០២៥ សរុបចំនួន ៥៩ អង្គភាព ដោយធ្វើការបែងចែកជា ៣ប្រភេទនៃអង្គភាពថវិការួមមាន៖ ១).អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាល ២).អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញនៅថ្នាក់កណ្តាល និង៣). អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅមន្ទីរជំនាញរាជធានី ខេត្តដូចខាងក្រោម៖




**រូបភាពទី១១៖** ស្ថានភាពអង្គភាពថវិកា

## ៥.៨. ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួង អយក (EFMS) ត្រូវបានរៀបចំឡើងដើម្បីជាចំណែកមួយក្នុងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយគ្របដណ្តប់ទាំងការរៀបចំថវិកា ការអនុវត្តថវិកា ការត្រួតពិនិត្យស្ថានភាពថវិកា កិច្ចបញ្ជិកាគណនេយ្យសម្ភារៈ និងសវនកម្ម ដែលត្រូវបានអភិវឌ្ឍដោយក្រុមការងារព័ត៌មានវិទ្យា នៃនាយកដ្ឋានហិរញ្ញវត្ថុដោយឈរលើគោលដៅ ៤ដំណាក់កាល រួមមាន៖

- ការបង្កើនភាពជឿទុកចិត្តបាននៃថវិកា
- គណនេយ្យភាពហិរញ្ញវត្ថុ
- ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ
- គណនេយ្យភាពសមិទ្ធកម្ម។

ស្របពេលដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តួចផ្តើមបង្កើតក្រុមការងារដើម្បីអភិវឌ្ឍន៍ប្រព័ន្ធ

EFMS និងអភិវឌ្ឍប្រព័ន្ធផ្សេងៗសម្រាប់ជាឧបករណ៍គាំទ្រដល់ការគ្រប់គ្រងថវិកានៅក្រសួងអប់រំ យុវជន និងកីឡា ដែលបានឆ្លងកាត់ដំណាក់កាលអភិវឌ្ឍសំខាន់ៗដូចខាងក្រោម៖

| 2011 (EFMS V1) | 2015 (EFMS V1) | 2017 (EFMS V2) | 2021 (EFMS V3.0) |
|---|---|---|---|
| • Developed by a private company sponsored by ADB Project | • Launched to CBE & POE | • Redevelop by EFMS Team | • petty cash Management<br>• Teacher Training Center Budget management |

| 2022 (EFMS V3.1) | 2023 (EFMS V3.2) | 2024 (EFMS V3.3) | 2025 (EFMS V3.4): |
|---|---|---|---|
| • Budget Allocation<br>• Purchase Order<br>• Account Payable<br>• Budget Movement and Accounting report<br>• Financial Report | • Mission Management<br>• School Operation Fund<br>• Development Partner Fund/Grant | • Development Partner Fund/Grant (count.),<br>• Budget Formulation,<br>• Procurement<br>• Account Receivable | • Fixed Asset<br>• Inventory<br>• Audit Trial |

## ៦. ទិសដៅអនុវត្តបន្ត

ជាវឌ្ឍនភាពនៃដំណើរការការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាកត្តាសត្យានុម័តក្រសួង អយក មានបញ្ហាប្រឈមមួយចំនួនជុំវិញការរៀបចំផែនការថវិកា ការអនុវត្តថវិកា និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ ដែលចាំបាច់ត្រូវធ្វើការកែលម្អ និងបន្តអភិវឌ្ឍដើម្បីទទួលបាននូវលទ្ធផលកាន់តែល្អប្រសើរ។ ក្នុងន័យនេះ ជាទិសដៅអនុវត្តបន្តក្រសួង អយក នឹងបន្តអាទិភាពលើការអនុវត្តយន្តការដូចខាងក្រោម៖

- បន្តបង្កើនស្វ័យភាព និងគណនេយ្យភាពហិរញ្ញវត្ថុ
- ពង្រឹង និងពង្រីកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បន្តពង្រឹងយន្តការរៀបចំ និងការអនុវត្តថវិកា
- កសាងសមត្ថភាពសម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤
- បន្តលើកកម្ពស់តម្លាភាពថវិកា
- គាំទ្រសាលារៀន ដើម្បីប្រែក្លាយជាសាលារៀនគំរូ
- ពង្រឹងយន្តការពិនិត្យតាមដាន និងវាយតម្លៃ

## ៧. សេចក្តីសន្និដ្ឋាន

ការធ្វើអភិបាលកិច្ចផ្តោតលើការអនុវត្តថវិកាសមិទ្ធកម្ម ជាឧបករណ៍សំខាន់មួយសម្រាប់តម្រង់ទិស លើការអនុវត្តថវិកាតាមរយៈទិដ្ឋភាពផលប្រយោជន៍សាធារណៈ តម្លាភាព គណនេយ្យភាព និរន្តរភាព ការគ្រប់គ្រង និងប្រសិទ្ធភាពល្អជាមូលដ្ឋានអនុវត្ត ដោយផ្សារភ្ជាប់ការទទួលខុសត្រូវខ្ពស់របស់គ្រប់អង្គភាពអនុវត្តនៃស្ថាប័នមួយ លើគ្រប់ដំណាក់កាលនៃការអនុវត្តថវិកា។ លទ្ធផលសម្រេចបានអាចជា មូលដ្ឋានវាយតម្លៃ និងកែលម្អ ដើម្បីធ្វើយ៉ាងណា អាចសម្រេចបាននូវគោលនយោបាយអប់រំដ៏ប្រសើរមួយ។

បើទោះជាយ៉ាងណាក៏ដោយ ការដោះស្រាយបញ្ហាប្រឈមទាំងនេះទាមទារនូវដំណោះស្រាយ ប្រកបដោយភាពច្នៃប្រឌិត ឆន្ទៈវិជ្ជាជីវៈ ការកសាងសមត្ថភាព និងប្រព័ន្ធត្រួតពិនិត្យដ៏រឹងមាំ។ តាមរយៈការជម្នះឧបសគ្គទាំងនេះ និងប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អ តាមរយៈការអនុវត្តថវិកាផ្តោតលើសមិទ្ធកម្មនឹងជំរុញឱ្យមានការកែលម្អប្រកបដោយអត្ថន័យ និងយូរអង្វែងក្នុងការគ្រប់គ្រងសាធារណៈ និងការគ្រប់គ្រងធនធាន ដែលផ្តល់អត្ថប្រយោជន៍ដល់សង្គមទាំងមូល។

Kingdom of Cambodia
Nation Religion King

Ministry of Education, Youth and Sports
Congress (2025)

# CONCEPT PAPER
# ON
# Ministry of Education, Youth and Sport Governance Through the Implementation of Result Based Budgeting

Prepared by: General Secretariat
Phnom Penh, February 5, 2025

## 1. Introduction

In response to the Pentagonal Strategy of the Royal Government of the 7th term, especially the first angle: human capital development, including strengthening the quality of education, sports, science and technology, training in technical skills, promoting health and well-being of the people, strengthening the social protection system and food system, and strengthening citizenship in a highly civilized, ethical, equitable and modern society, the Ministry of Education, Youth and Sport continues to work actively, having become a habit of implementing the foundation of continuous education sector reform strategies, always moving forward with proactivity and high professional responsibility as an educational institution.

This concept note was created to promote knowledge on linking governance principles to the implementation of performance-based budgeting, so that all public institutions, private institutions, and especially the public can understand the national budget information used by the Ministry of Education, Youth and Sport based on the basic principles of the governance, as well as being part of a mechanism to provide concise, easy-to-understand, context-appropriate and simple information.

## 2. Vision

The vision of good governance through the implementation of performance budgeting in the context of the Ministry of Education, Youth and Sport is influenced by the vision of education policy, which stipulates that Cambodians "have high knowledge and at least one skill for life" through the establishment of a budget system linked to conditions of transparency, accountability and results that increase the efficiency of resource allocation, increase financial efficiency and improve educational outcomes. The vision is also part of achieving the objectives of ensuring that budget decisions are in line with national development goals, promote equity in the education sector, support and respond positively to the growth of all aspects of demand, and be sustainable in the sector.

## 3. Mission

